ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី

លេខ......០៩៥.........កកន/ប្រក

# ប្រកាស
# ស្តីពី
# ការតែងតាំងសមាសភាពក្រុមការងារដើម្បីកុមារ នៃក្រសួងកិច្ចការនារី

## រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ នស/៩៤ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ០៦/នស/៩៤ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- យោងសេចក្តីសម្រេចលេខ ១២៧ កជក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០១០ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

## សម្រេច

ប្រការ១ : ត្រូវបានតែងតាំងសមាសភាពក្រុមការងារដើម្បីកុមារនៃក្រសួងកិច្ចការនារី ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-លោកជំទាវ | ស៊ីវណ្ណ បុទុម | រដ្ឋលេខាធិការ | ប្រធាន |
| ២-លោកជំទាវ | ឡូ គីម | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣-លោកស្រី | ឡុង និមល | អគ្គនាយករង | អនុប្រធានអចិន្ត្រៃយ៍ |
| ៤-លោកស្រី | ថួង រដ្ឋធី | អគ្គលេខាធិការរង | សមាជិកា |
| ៥-លោកស្រី | តែ រួចលីម | ប្រធាននាយកដ្ឋាន | សមាជិកា |
| ៦-លោកស្រី | នុំ បុប្ផារី | ប្រធាននាយកដ្ឋាន | សមាជិកា |
| ៧- លោកស្រី | កេត ម៉ារឌី | ប្រធាននាយកដ្ឋាន | សមាជិកា |
| ៨- លោកស្រី | ញាណ សុចិត្រា | ប្រធាននាយកដ្ឋាន | សមាជិកា |
| ៩- លោកស្រី | ហ៊ូ និរមិត្តា | ប្រធាននាយកដ្ឋាន | សមាជិកា |
| ១០- លោកស្រី | ឌី រ៉ានី | ប្រធាននាយកដ្ឋាន | សមាជិកា |
| ១១-លោកស្រី | ហែម ម៉ារី | អនុប្រធាននាយកដ្ឋាន | សមាជិកា |

ប្រការ២ : ក្រុមការងារដើម្បីកុមារនៃក្រសួងកិច្ចការនារី មានតួនាទីនិងភារកិច្ច៖

-ពិគ្រោះយោបល់ សម្របសម្រួលសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហាកុមារនៅក្រសួងកិច្ចការនារី

អាគារលេខ ៣ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ (ភ្នំពេញ)
ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៤២៦ ៥៣៩ / ២៣ ៤២៦ ៥១៥
ទូរស័ព្ទ : (៨៥៥) ២៣ ២១៦ ៧០៤

-ពិនិត្យ តាមដាន វាយតម្លៃលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ កម្មវិធីជាតិសម្រាប់កុមារនិង លើកសំណើជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ "ក.ជ.ក" ពាក់ព័ន្ធនឹងបញ្ហានានារបស់កុមារ និងបំផុសចលនាគាំទ្រការអនុវត្តសិទ្ធិកុមារឲ្យមានប្រសិទ្ធភាព

-រៀបចំផែនការ កម្មវិធី និងសកម្មភាពផ្សេងៗ ដើម្បីឧត្តមប្រយោជន៍កុមារ សម្រាប់មន្ត្រីរាជការមានជាអាទិ៍ ៖ ការគោរពនិងការអនុវត្តសិទ្ធិកុមារ ការរស់រានមានជីវិត ការអភិវឌ្ឍន៍ ការការពារ ការលើកកម្ពស់សុខុមាលភាព ការចូលរួមចំណែករបស់កុមារ ការប្រឆាំងនឹងអំពើហិង្សា ការទប់ស្កាត់ ការលុបបំបាត់ការកេងប្រវ័ញ្ចគ្រប់រូបភាពមកលើកុមារ និងប្រឆាំងនឹងការជួញដូរគ្រឿងញៀន

-បញ្ជ្រាបការងារកុមារទៅក្នុងកម្មវិធីការងាររបស់ក្រសួងកិច្ចការនារី

-ធ្វើទំនាក់ទំនងជាមួយអង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ដែលមានគម្រោងការងារពាក់ព័ន្ធនឹងកុមារជាកូនចៅមន្ត្រីរាជការក្រសួងកិច្ចការនារី ដើម្បីរកជំនួយឧបត្ថម្ភនិងផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ ទស្សនៈកិច្ចច្រើន ដែលទាក់ទងនឹងគោលដៅរួមក្នុងការកែលម្អស្ថានភាពកុមារជាកូនចៅមន្ត្រីរាជការក្រសួងកិច្ចការនារី

-រៀបចំមូលដ្ឋានទិន្នន័យ ស្តីពីស្ថានភាពកុមារជាកូនចៅមន្ត្រីរាជការក្រសួងកិច្ចការនារី

-រៀបចំទិវាកុមារអន្តរជាតិ ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា

-ចាត់ចែងអនុវត្តរាល់គោលការណ៍ ផែនការសកម្មភាពរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ "ក.ជ.ក"

-អនុវត្តភារកិច្ចផ្សេងៗទៀតដែល **ក.ជ.ក** ប្រគល់ជូន ។

ប្រការ៣ : ក្រុមការងារដើម្បីកុមារនៃក្រសួងកិច្ចការនារី ត្រូវជួបប្រជុំយ៉ាងតិច២ (ពីរ) ដងក្នុងមួយឆ្នាំ។ ក្នុងករណីចាំបាច់ ក្រុមការងារដើម្បីកុមារនៃក្រសួងកិច្ចការនារី អាចប្រជុំជាវិសាមញ្ញតាមការអញ្ជើញរបស់ប្រធាន។ ក្រុមការងារដើម្បីកុមារនៃក្រសួងកិច្ចការនារី ត្រូវធ្វើការបូកសរុបរបាយការណ៍ អំពីលទ្ធផលនៃការអនុវត្តសកម្មភាពការងារប្រចាំត្រីមាស ឆមាស និងឆ្នាំ ក្នុងក្រសួងកិច្ចការនារី ព្រមទាំងលើកសំណូមពរចាំបាច់មក **ក.ជ.ក** ។

ប្រការ៤ : នាយកដ្ឋានស្ត្រី និងការអប់រំ នៃអគ្គនាយកដ្ឋានអភិវឌ្ឍសង្គម ជាលេខាធិការឲ្យក្រុមការងារដើម្បីកុមារនៃក្រសួងកិច្ចការនារី

ប្រការ៥ : អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ ប្រធានគ្រប់នាយកដ្ឋាន អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងសមាសភាពក្នុងប្រការ១ ត្រូវអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១២

រដ្ឋមន្ត្រី

អ៊ឹង កន្thaផាវី

ចម្លងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- ថ្នាក់ដឹកនាំក្រសួងកិច្ចការនារី "ដើម្បីជូនជ្រាប"
- ដូចប្រការ១ និងប្រការ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ "កាលប្បវត្តិ"